# រោគរបេង



## តើអ្វីទៅជារោគរបេង (TB)?

រោគរបេង TB គឺជាការឆ្លងរោគ ឬជំងឺដែលបង្កដោយមេរោគដែលអ្នកដកដង្ហើមចូលក្នុងសួតរបស់អ្នក។ រោគរបេង TB មានពីរប្រភេទ ៖ ការឆ្លងរោគរបេង TB និងជំងឺរបេង TB។

## តើអ្វីទៅជាការឆ្លងរោគរបេង TB?

ការឆ្លងរោគរបេង TB គឺជាប្រភេទរោគរបេង TB ដែលអ្នកមានចំនួនមេរោគរបេង TB តិចតួច ដែលនៅសល់មានជីវិតក្នុងរាងកាយរបស់អ្នក ប៉ុន្តែវាមិនមានគ្រោះថ្នាក់ចំពោះអ្នកឡើយ។ ការការពាររាងកាយរបស់អ្នក (ប្រព័ន្ធការពាររាងកាយពីជំងឺរបស់អ្នក) នឹងរក្សាមេរោគរបេងពីការបង្កបញ្ហានានា។ អ្នកមានអារម្មណ៍ល្អ អ្នកមិនឈឺ ហើយអ្នកមិនអាចចម្លងមេរោគរបេង TB ទៅអ្នកណាម្នាក់។ បើអ្នកមានការឆ្លងរោគរបេង TB ហើយប្រព័ន្ធការពាររាងកាយពីជំងឺរបស់អ្នកទៅជាទន់ខ្សោយពីជំងឺផ្សេងទៀត ឬពីឱសថដែលអ្នកអាចពិសានោះ ការឆ្លងរោគរបេង TB របស់អ្នក អាចវិវត្តន៍ទៅជាជំងឺរបេង TB។ ពេលខ្លះការឆ្លងរោគរបេង TB ហៅថារោគរបេង TB "ដែលសម្ងំ " ឬ "ដេក"។

## តើអ្វីទៅជាជំងឺ TB?

ជំងឺរបេង TB គឺជាប្រភេទរោគរបេង TB ដែលអ្នកមានចំនួនមេរោគរបេង TB ដ៏ច្រើន ដែលមានជីវិតក្នុងរាងកាយរបស់អ្នក ហើយមេរោគនានានឹងបង្កឱ្យមានគ្រោះថ្នាក់។ តាមធម្មតាអ្នកមានអារម្មណ៍ថាឈឺ ហើយជានិច្ចកាលអ្នកអាចចម្លងមេរោគរបេង TB ទៅអ្នកដទៃទៀត។ ជំងឺរបេង TB អាចត្រូវបានរកឃើញនៅក្នុងផ្នែកណាមួយនៃរាងកាយរបស់អ្នក ប៉ុន្តែធម្មតាមានផលប៉ះពាល់ដល់សួតរបស់អ្នក។ រោគសញ្ញាជំងឺរបេង TB ធម្មតាភាគច្រើនគឺ **ក្អក**, **គ្រុនក្តៅខ្លួន**, **ការបាត់បង់ចំណង់បរិភោគ**, **ការបាត់បង់ទម្ងន់**, **ភាពខ្សោយ**, **ការបែកញើសពេលយប់ និងមានអារម្មណ៍ហត់**។

## តើអ្នកឆ្លងជំងឺរបេង TB យ៉ាងដូចម្តេច?

មេរោគរបេង TB ចូលទៅក្នុងខ្យល់ នៅពេលអ្នកណាម្នាក់មានជំងឺរបេង TB ក្នុងសួត ក្អក កណ្តាស់ និយាយ ឬច្រៀង។ មនុស្សដែលកំពុងរស់នៅ ធ្វើការ ឬចំណាយពេលយ៉ាងច្រើនជាមួយបុគ្គលនេះ ដែលដកដង្ហើមខ្យល់ដូចគ្នា។ ពួកគេអាចដកដង្ហើមចូលមេរោគរបេង TB ហើយឆ្លងជំងឺរបេង TB។

អ្នកមិនអាចឆ្លងមេរោគរបេង TB ពីមនុស្សម្នាក់ដែលមានការឆ្លងរោគរបេង TB ឡើយ។

## តើអ្នកអាចឆ្លងមេរោគរបេង TB ពីការចែករំលែកអាហារឬទេ?

ទេ។ មេរោគរបេង TB ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមខ្យល់តែប៉ុណ្ណោះ។ អ្នកមិនអាចឆ្លងមេរោគរបេង TB តាមការចែករំលែកអាហារ ឬការឱ្យអាហារ ឬវត្ថុផ្សេងៗទៀតឡើយ។

## តើអ្នកណាស្ថិតក្នុងហានិភ័យចំពោះការឆ្លងជំងឺរបេង TB?

មនុស្សស្ថិតក្នុងហានិភ័យចំពោះការឆ្លងជំងឺរបេង TB គឺអ្នកទាំងនោះដែលបានទាក់ទងមនុស្សដែលមានជំងឺរបេង TB នៅអំឡុងពេលពួកគេក្អកមានមេរោគរបេង TB ចូលទៅក្នុងខ្យល់។ មនុស្សដែលបានរស់នៅតំបន់នានានៃពិភពលោកដែលជាទីកន្លែងមានមេរោគរបេង TB យ៉ាងច្រើន ដែលស្ថិតកម្រិតហានិភ័យចំពោះការឆ្លងរោគរបេង TB។

## តើមានការធ្វើតេស្តចំពោះការឆ្លងរោគរបេង TB ឬទេ?

បាទ/ចាស៎។ មានប្រភេទខុសគ្នាចំនួនពីរសម្រាប់ការធ្វើតេស្តចំពោះការឆ្លងរោគរបេង TB គឺការធ្វើតេស្តឈាម និងការធ្វើតេស្តស្បែក។ ការធ្វើតេស្តទាំងពីរនេះ អាចរកឃើញ បើអ្នកមានមេរោគរបេង TB ក្នុងរាងកាយរបស់អ្នក។ ដោយមានការធ្វើតេស្តឈាមនោះ បរិមាណឈាមរបស់អ្នកតិចតួច ត្រូវបានយកសម្រាប់ការធ្វើតេស្តនេះ។ ដោយមានការធ្វើតេស្តស្បែកនោះ បរិមាណវត្ថុរាវតិចតួច ត្រូវដាក់ក្រោមស្បែកកំភួនដៃ។ អ្នកនឹងត្រូវការវិលត្រឡប់មកវិញក្នុងរយៈពេលពីរ ឬបីថ្ងៃ ដើម្បីឱ្យវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាឬគិលានុបដ្ឋាយិការបស់អ្នក ពិនិត្យមើលលទ្ធផលនៃការធ្វើតេស្តស្បែក។ បើការធ្វើតេស្តរោគរបេង TB របស់អ្នកគឺវិជ្ជមានឬឱ្យហេតុថាមានជំងឺ វាមានន័យថាអ្នកមានមេរោគរបេង TB ហើយវេជ្ជបណ្ឌិតរបស់អ្នកអាចបញ្ជាឱ្យមានការថតអ៊ិចរ៉េ X-ray ដើមទ្រូង ដើម្បីធ្វើឱ្យប្រាកដថាអ្នកមិនឈឺដោយជំងឺរបេង TB។

## តើការឆ្លងរោគរបេង TB អាចព្យាបាលឬទេ?

បាទ/ចាស៎។ វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាឬគិលានុបដ្ឋាយិការបស់អ្នក អាចផ្តល់ជូនអ្នកនូវឱសថចំនួនមួយ ឬច្រើន ដើម្បីព្យាបាលការឆ្លងរោគរបេង TB ។ អ្នកនឹងញ៉ាំថ្នាំរយៈពេល 3 ដល់ 9 ខែ អាស្រ័យលើឱសថ។ វាមានសារៈសំខាន់ណាស់ដើម្បីញ៉ាំថ្នាំសម្រាប់ការឆ្លងរោគរបេង TB ដូច្នេះវាមិនវិលត្រឡប់ទៅរកជំងឺរបេង TB ឡើយ។

## តើជំងឺរបេង TB អាចព្យាបាលឬទេ?

បាទ/ចាស៎។ បើអ្នកមានជំងឺរបេង TB អ្នកនឹងញ៉ាំថ្នាំរោគរបេង TB ជាច្រើន រយៈពេលយ៉ាងតិច 6 ខែ ដើម្បីព្យាបាលជំងឺរបេង TB។

## តើអ្វីទៅជាជំងឺរបេង TB ដែលមានរ៉េស៊ីស្តង់ឬស៊ាំនឹងថ្នាំ?

ជំងឺរបេង TB ដែលមានរ៉េស៊ីស្តង់ឬស៊ាំនឹងថ្នាំ បង្កពីមេរោគរបេង TB ដែលមិនអាចសម្លាប់ដោយប្រើថ្នាំធម្មតា។ បើអ្នកមានជំងឺរបេង TB ដែលមានរ៉េស៊ីស្តង់ឬស៊ាំនឹងថ្នាំ អ្នកអាចត្រូវញ៉ាំថ្នាំរោគរបេង TB ខុសៗគ្នា និងច្រើនថែមទៀត រយៈពេលយ៉ាងតិច 12 ខែ។ ជំងឺរបេងTB អាចក្លាយជារ៉េស៊ីស្តង់ឬស៊ាំនឹងថ្នាំ បើអ្នកកមិនញ៉ាំថ្នាំរោគរបេង TB របស់អ្នក ស្របតាមការណែនាំ ឬបើអ្នកឈប់ញ៉ាំថ្នាំមុនការព្យាបាលរបស់អ្នក ត្រូវបានបញ្ចប់។ អ្នកអាចឆ្លងជំងឺ TB ដែលមានរ៉េស៊ីស្តង់ឬស៊ាំនឹងថ្នាំ បើមេរោគដែលអ្នកបានដកដង្ហើមចូលនោះ មកពីមនុស្សមានជំងឺរបេង TB ដែលមានរ៉េស៊ីស្តង់ឬស៊ាំនឹងថ្នាំ។

## តើអ្វីទៅជា BCG?

BCG គឺជាថ្នាំបង្ការប្រឆាំងនឹងរោគរបេង TB ដែលត្រូវបានផ្តល់ជូនប្រទេសនានាដែលជាទីកន្លែងរោគរបេង TB ដែលឃើញមានគ្រប់កន្លែង។ វាអាចជួយការពារទារក និងកុមារតូចៗពីការឈឺពីជំងឺរបេង TB ។ ថ្នាំ BCG ដែលល្អបំផុតការពារកុមារៗរហូតដល់ 5 ឆ្នាំ ហើយពេលខ្លះវាមិនការពារប្រឆាំងនឹងរោគរបេង TB ឡើយ។ ថ្នាំនេះកម្រប្រើប្រាស់ នៅសហរដ្ឋអាមេរិក។

## តើថ្នាំបង្ការរោគ BCG អាចបង្កឱ្យមានការធ្វើតេស្តរោគរបេង TB វិជ្ជមានឬឱ្យហេតុថាមានជំងឺឬទេ?

ថ្នាំ BCG មិនបង្កឱ្យមានលទ្ធផលនៃការធ្វើតេស្តវិជ្ជមានឬឱ្យហេតុថាមានជំងឺឡើយ។ តាមធម្មតាលទ្ធផលនៃការធ្វើតេស្តស្បែករោគរបេង TB វិជ្ជមានឬឱ្យហេតុថាមានជំងឺពីមេរោគរបេង TB នៅក្នុងរាងកាយ, មិនមែនមកពីថ្នាំបង្ការ BCG ឡើយ។

សម្រាប់ព័ត៌មានបន្ថែមអំពីរោគរបេង TB សូមទាក់ទងមកគណៈកម្មការទីក្រុងឬទីក្រុងតូចៗ ឬក្រសួងសុខាភិបាលសាធារណៈរដ្ឋម៉ាសាជូសេត Massachusetts, កម្មវិធីរោគរបេងតាមលេខ ៖ (617) 983-6970 ឬ http://www.mass.gov/dph/cdc/tb/។